ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ អង្គារ ៩ រោច ខែ អាសាឍ ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤*
*រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០២០*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលកិច្ចប្រជុំគណៈកម្មាធិការសកម្មភាពគោលនយោបាយលើកស្ទួយសហគ្រាសធុនតូច និងមធ្យម លើកទី ១

នាព្រឹកថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០២០, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការសកម្មភាពគោលនយោបាយលើកស្ទួយសហគ្រាសធុនតូច និងមធ្យម **(គ.ស.ស.)** បានដឹកនាំ ***“កិច្ចប្រជុំគណៈកម្មាធិការសកម្មភាពគោលនយោបាយលើកស្ទួយសហគ្រាសធុនតូច និងមធ្យម លើកទី ១”*** ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី និងថ្នាក់ដឹកនាំក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលជាសមាជិកនៃគណៈកម្មាធិការ ដើម្បីពិនិត្យ និងអនុម័តលើសំណើវិធានការដើម្បីលើកស្ទួយសហគ្រាសធុនតូច និងមធ្យម (Small and Medium Enterprises - SMEs) សម្រាប់រយៈពេលបន្ទាន់, ខ្លី និងមធ្យម ។

ឯកឧត្តម **ផាន់ ផល្លា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **(គ.ស.ហ)** បានរាយការណ៍ជូនអង្គប្រជុំអំពីលទ្ធផលស្រាវជ្រាវដោយគូសរំលេចបញ្ហាប្រឈមដែលមានលក្ខណៈជារចនាសម្ព័ន្ធ និងជាប្រព័ន្ធអេកូឡូស៊ី ពិសេស ពាក់ព័ន្ធនឹង÷ ១. បន្ទុកអនុលោមភាព, ការអនុវត្តបទប្បញ្ញត្តិដែលនៅមិនទាន់ស៊ីចង្វាក់រវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ និងភាពនៅមានកម្រិតក្នុងការផ្តល់សេវាគាំទ្រធុរកិច្ច, ២. សមត្ថភាព SMEs ក្នុងការគ្រប់គ្រងបច្ចេកទេស ផលិតកម្ម, ធុរកិច្ច និងហិរញ្ញវត្ថុនៅមានកម្រិតទាប និង ៣. ការទទួលបានហិរញ្ញវត្ថុនៅមានគម្លាតធំ ។

អង្គប្រជុំបានពិភាក្សា និងឯកភាពជាគោលការណ៍លើវិធានការលើកស្ទួយ SMEs ដោយគូររៀបចំជាពីរដំណាក់កាល÷

***១. វិធានការរយៈពេលបន្ទាន់ផ្តោតលើ÷***

ក. ការកាត់បន្ថយ និងសម្រួលនូវបន្ទុកអនុលោមភាពសម្រាប់សហគ្រាសធុនតូច និងមធ្យម,

ខ. ការពិនិត្យលទ្ធភាពក្នុងការផ្តល់សេវាកម្មគាំទ្រ ដូចជាប្រឹក្សាយោបល់ធុរកិច្ច, សេវាមេធាវី និងប្រឹក្សាច្បាប់, ការចុះបញ្ជី, គណនេយ្យ, ទីផ្សារ និងបច្ចេកទេស, និង

គ. ជំរុញការគាំទ្រ ការផ្តល់ហិរញ្ញប្បទានដល់ SMEs តាមរយៈធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា និងធនាគារ អភិវឌ្ឍន៍ជនបទ និងកសិកម្ម ។

***២. វិធានការរយៈពេលខ្លី និងមធ្យម ផ្តោតលើ៖***

ការគាំទ្រជាប្រព័ន្ធអេកូឡូស៊ី រួមមាន ការបន្តកំណែទម្រង់ក្របខ័ណ្ឌបទប្បញ្ញត្តិ និងការអនុវត្ត, ការលើកកម្ពស់សេវាគាំទ្រធុរកិច្ច, ការគាំទ្រហិរញ្ញវត្ថុ, ការលើកកម្ពស់ទីផ្សារ សម្រាប់ SMEs, ជំរុញ និងលើកកម្ពស់ធនធានមនុស្ស និង R&D, និងលើកកម្ពស់ផ្នត់គំនិតសហគ្រិនភាព ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ប្រធានអង្គប្រជុំបានគូសបញ្ជាក់ជារួមថា ក្នុងការជួយគាំទ្រ SMEs និងការដោះស្រាយបញ្ហាប្រឈមរបស់ SMEs ត្រូវការការសម្របសម្រួល និងការដោះស្រាយជាប្រព័ន្ធ និងស្មារតីចូលរួមចំណែករស់រវើកជាលក្ខណៈអន្តរក្រសួង-ស្ថាប័ន ដើម្បីឱ្យ SMEs អាចមានលទ្ធភាពគ្រប់គ្រាន់ចូលរួមវិភាគទានដល់កំណើនសេដ្ឋកិច្ច, បង្កើតការងារ និងចំណូលជាក់ស្តែងដល់ប្រជាពលរដ្ឋ, បំពេញតម្រូវការក្នុងស្រុក ក៏ដូចជាលើកកម្ពស់សក្តានុពលសេដ្ឋកិច្ច ។ ដើម្បីធានាបានប្រសិទ្ធភាពអនុវត្តន៍, ជាកិច្ចការបន្ត ត្រូវធ្វើការសិក្សាឱ្យបានជាក់លាក់ តាមរយៈ ការកំណត់នូវនិយមន័យ, វិសាលភាព (Scope) ក៏ដូចជា ផលរបរនៃ SMEs, លទ្ធភាពជ្រោមជ្រែងផ្នែកហិរញ្ញវត្ថុ, រៀបចំលិខិតបទដ្ឋានគតិយុត្តិដែលប្រទាក់ក្រឡា ក៏ដូចជា រៀបចំនូវសូចនាកររវាស់វែង និងការតាមដានការអនុវត្តន៍ជាអន្តរវិស័យ និងស្ថាប័ន ។

ជាចុងក្រោយ, **ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណឯកឧត្តម លោកជំទាវរដ្ឋមន្ត្រី និងថ្នាក់ដឹកនាំក្រសួង-ស្ថាប័នពាក់ព័ន្ធ ព្រមទាំងបានវាយតម្លៃខ្ពស់ដល់ក្រុមការងារ ដែលបានខិតខំបំពេញការងារ ផ្តល់ធាតុចូលបន្ថែម និងមានឆន្ទៈមុតមាំក្នុងការចូលរួមដោះស្រាយបញ្ហាប្រឈមសម្រាប់លើកស្ទួយ SMEs នៅកម្ពុជា ។